**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...១៤៥... សហវ.......

រាជធានីភ្នំពេញ ថ្ងៃទី...១៤... ខែ...មីនា... ឆ្នាំ ២០០៣

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើត និង តែងតាំងភ្នាក់ងារបើកផ្តល់ សំរាប់បើកបៀវត្សរ៍និងប្រាក់អន្តរាគមន៍ ក្នុងវិស័យសង្គមកិច្ច និង ចប្បមបំរុងមន្ត្រីរាជការនៅស្នងការដ្ឋាន នគរបាលខេត្ត បាត់ដំបង

**- ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**- សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម លេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២

-បានឃើញព្រះរាជក្រម លេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

-បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ/ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃ គណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី១៦ខែមករាឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

## សំរេច

**ប្រការ១:** ប្រាក់បៀវត្សរ៍មន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ នៃស្នងការដ្ឋាននគរបាលខេត្ត បាត់ដំបង នឹងត្រូវបើកផ្តល់តាមរយៈ (ភ្នាក់ងារបើកផ្តល់) ។

**ប្រការ២:** ត្រូវបានតែងតាំង :

-លោកវរៈសេនីយ៍ត្រី **សុខណ្ណា គឹមឃាក់** ឋានៈនាយការិយាល័យផែនការគណនេយ្យ ជាភ្នាក់ងារបើកផ្តល់ ។

-លោកអនុសេនីយ៍ឯក **ឌុំ រ៉ែណូ** ឋានៈនាយរងការិយាល័យផែនការគណនេយ្យ ជាភ្នាក់ងារបើកផ្តល់ជំនួស ។

**ប្រការ៣:** លោក **សុខណ្ណា គឹមឃាក់** និងលោក **ឌុំ រ៉ែណូ** ត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើនៅធនាគារជាតិ ដើម្បីទទួលមូលនិធិ សំរាប់យកទៅបើកបៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ជូនមន្ត្រីរាជការ ។

**ប្រការ៤:** បែបបទនៃការអនុវត្តន៍បើកផ្តល់បៀវត្សរ៍ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ត្រូវបានកំណត់ដោយសេចក្តី ណែនាំជាក្រោយ ។

**ប្រការ៥:** ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាសនិងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

**ប្រការ៦:** សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៧:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានធនាគារជាតិ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធទាំងអស់ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នងការនគរបាលខេត្ត បាត់ដំបង លោក **សុខណ្ណា គឹមឃាក់** និងលោក **ឌុំ រ៉ែណូ** មានភារកិច្ចទទួលបន្ទុកអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង យូ ហុកគ្រី

កន្លែងទទួល:

- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- -ដូចប្រការ៧ "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ-ឯកសារ